# បដិមាព្រះព្រហ្មរកឃើញនៅតំបន់វត្តបាសែត

ព្រះព្រហ្ម គឺជាទេពដ៏សំខាន់មួយក្នុងចំណោមទេពធំៗទាំងបីនៃព្រហ្មញ្ញសាសនា។ ព្រះព្រហ្ម មានតួនាទីបង្កើតលោកដូចព្រះឥសូរដែរ។ នៅក្នុងគម្ពីរមហាភារត ព្រះព្រហ្មកើតចេញពីផ្កាឈូក ដែលដុះចេញពីផ្ចិតព្រះនារាយណ៍ ហើយជាទូទៅគេនិទានថាព្រះព្រហ្មមានពណ៌ក្រហម មាន ព្រះហស្តបួន និងព្រះសិរបួន។ នៅសម័យដំបូង (ស.វ.ទី៧-៨) គេតែងឃើញសិលាចារឹកជាច្រើន និយាយរៀបរាប់អំពីការឧទ្ទិសដល់ព្រះព្រហ្ម ប៉ុន្តែបើជាបដិមាទោលវិញគេរកឃើញតិចតួចប៉ុណ្ណោះ (ឧទាហរណ៍ បដិមាព្រះព្រហ្មរកឃើញនៅសំបូរព្រៃគុក)។ មកដល់សម័យអង្គរ ការសាងបដិមា ព្រះព្រហ្មហាក់មានសន្ទុះឡើងជាងពេលមុន។ នៅក្នុងអត្ថបទខ្លីនេះ យើងនឹងបង្ហាញអំពីបដិមា ព្រះព្រហ្មមួយដែលរកឃើញនៅតំបន់វត្តបាសែត។

បដិមានេះ ជាអំណោយរបស់លោក M.Fustier ដែលជានិយោជិតប្រៃសណីយ និងទូរគម-នាគមន៍ ជូនដល់សារមន្ទីរ Trocadéro ក្នុងទីក្រុងប៉ារីស នៅក្នុងខែមេសា ឆ្នាំ១៨៨៨ ហើយបានបញ្ជូន បន្តទៅដាក់តាំងបង្ហាញនៅសារមន្ទីរជាតិហ្គីមេត នៅក្នុងឆ្នាំ១៩២៧ ដូចវត្ថុបុរាណ ៥០ ដុំផ្សេងទៀត របស់ខ្មែរដែរ។ បើទោះបីបដិមានេះត្រូវគេអះអាងថារកឃើញនៅតំបន់វត្តបាសែត ខេត្តបាត់ដំបង ក៏ពិតមែន ប៉ុន្តែមកទល់បច្ចុប្បន្នគេពុំទាន់អាចដឹងច្បាស់ថា បដិមានេះរកឃើញនៅប្រាសាទណាមួយ ឱ្យប្រាកដឡើយ។ អ្នកជំនាញការនៅសារមន្ទីរហ្គីមេត ប្រទេសបារាំង យល់ថា ប្រាសាទវត្តបាសែត នៅខេត្តបាត់ដំបង សាងឡើងនៅក្នុងរជ្ជកាលព្រះបាទសូរ្យវរ្ម័នទី១ (គ.ស.១០០២-១០៤៩) ពោល គឺនៅ ស.វ.ទី១១ ប៉ុន្តែបដិមាព្រះព្រហ្មនេះអាចស្ថិតនៅក្នុងរចនាបថកោះកេរ នាស.វ.ទី១០ ដូច្នេះ ហើយ បដិមានេះមិនសមទំនងតម្កល់នូវប្រាសាទវត្តបាសែតនោះឡើយ។ អ្នកជំនាញការគិតថា បដិមានេះគួរតែមានប្រភពដើមស្ថិតនៅទីសក្ការបូជាណាមួយ ដែលស្ថិតនៅមិនឆ្ងាយពីប្រាសាទ វត្តបាសែត។ លោក Pierre Baptiste យល់ថា បដិមានេះប្រហែលជាមានប្រភពដើមមកពីប្រាសាទ អូរដំបង ដែលស្ថិតនៅប្រមាណ ១៥ គីឡូម៉ែត្រពីក្រុងបាត់ដំបង។ លោកយល់បែបនេះដោយ ហេតុថា ទីតាំងនេះធ្លាប់រកឃើញសិលាចារឹកមួយដែលមិនមានកាលបរិច្ឆេទ តែមាននិយាយ រៀបរាប់ពីព្រះបាទជ័យវរ្ម័ន ហើយជាទីតាំងប្រាសាទបែកបាក់ដែលមានតួប៉មចំនួន ៣ យោងទៅ តាមការរៀបរាប់របស់លោក Robert Dalet នៅឆ្នាំ១៩៣៧។ ការដែលមានតួប៉ម ៣ នេះ គឺគេនឹក ឃើញទៅដល់រជ្ជកាលព្រះបាទយសោវរ្ម័នទី១ ដែលជារឿយៗប្រាសាទនៅក្នុងរាជ្យរបស់ទ្រង់តែង

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

មានតួប៉ម ៣ តម្កល់អាទិទេពធំៗទាំងបី (ត្រីមូរ្តិ) គឺព្រះឥសូរ ព្រះវិស្ណុ និងព្រះព្រហ្ម តួយ៉ាងដូចជា ប្រាសាទភ្នំបូក និងប្រាសាទភ្នំក្រោម ជាដើម។

បដិមាព្រះព្រហ្មដែលរកឃើញនៅតំបន់ប្រាសាទវត្តបាសែត ខេត្តបាត់ដំបង មានកម្ពស់ ១៤៧ស.ម. ទទឹង ៩៧ស.ម.។ បដិមានេះ សាងឡើងដោយថ្មភក់ ក្នុងទម្រង់អង្គុយអង្គុយនៅលើទម្រផ្កាឈូករាងបួនជ្រុងស្មើ ក្នុងរបៀបអង្គុយមួយប្រភេទដែលហៅថា "បទ្មសន" ដែលសំដៅដល់កាយវិការអង្គុយដាក់ជើងទាំងពីររៀបស្មើត្រួតលើគ្នា (ខ្មែរច្រើនហៅថា ពែនភ្នែន)។ បដិមានេះ មានព្រះសិរបួន ព្រះហស្តបួន (ព្រះហស្តទាំងបួនបាក់ដូចគ្នាទាំងអស់ ដែលភាគច្រើននៅសល់ខាងដើមដៃ)។ ទ្រង់ពាក់មកុដក្នុងទម្រង់ជា "ជដាមកុដ" (មកុដរាងជាផ្នួងសក់) ហើយបើធៀបជាមួយមកុដរបស់បដិមាព្រះព្រហ្មរកឃើញនៅភ្នំបូក គឺមានលក្ខណៈស្ទើរតែដូចគ្នាតែម្តង។ ទម្រង់ព្រះភក្ត្រ ទៀតសោត ក៏មិនសូវខុសគ្នាប៉ុន្មានពីបដិមាព្រះព្រហ្មដែលរកឃើញនៅរចនាបថបាខែងឡើយ។ ប៉ុន្តែអ្វីដែលគេអាចសម្គាល់បានថាវាទំនងជាសិល្បៈរចនាបថកោះកេរ គឺទំហំបដិមា និងការតុបតែងសំពត់របស់បដិមា ដែលបង្ហាញពីសំពត់មានជាយធំមួយធ្លាក់មកបាំងខ្សែក្រវ៉ាត់។ នៅលើព្រះកាយរបស់បដិមាព្រះព្រហ្មនេះ សិល្បករតុបតែងជាគ្រឿងអលង្ការផ្សេងៗដូចជា ខ្សែក ខ្សែឈៀងដងខ្លួនពីរជាន់។ ប្រសិនបើប្រៀបធៀបបដិមាព្រះព្រហ្មនេះ ជាមួយនឹងបដិមាព្រះព្រហ្មរកឃើញនៅស.វ.ទី៧ក្នុងតំបន់ប្រាសាទសំបូរព្រៃគុក គឺមានលក្ខណៈខុសគ្នាឆ្ងាយខ្លាំងណាស់ ព្រោះបដិមាព្រះព្រហ្មនេះសាងឡើងក្នុងទម្រង់អង្គុយនិងមានមាឌធំសម្បើម រីឯបដិមាព្រះព្រហ្មនៅសំបូរព្រៃគុកសាងឡើងក្នុងទម្រង់ឈរនិងមានមាឌតូច។

ជារួមមក បដិមាព្រះព្រហ្មដែលរកឃើញនៅតំបន់ប្រាសាទវត្តបាសែត ខេត្តបាត់ដំបង គឺជាស្នាដៃសិល្បៈមួយយ៉ាងឥតខ្ចោះដែលសិល្បករខ្មែរនៅជំនាន់នោះបានបង្កើតឡើងឱ្យស្របទៅនឹងទស្សនវិជ្ជាហិណ្ឌូសាសនាដែលគេគោរពប្រណិប័តន៍នៅសម័យនោះ។ ភស្តុតាងនេះ គឺបាន សបញ្ជាក់ឱ្យឃើញថា ការសាងបដិមាព្រះព្រហ្មនៅរវាងចុងស.វ.ទី៩ រហូតដល់ពាក់កណ្តាលស.វ.ទី១០ គឺមានភាពលេចធ្លោគួរកត់សម្គាល់ ហើយជាទូទៅគេនិយមសាងមានទំហំធំៗជាងនៅសម័យដំបូងៗ៕

## ឯកសារយោង


Baptiste, P. & Zéphir, T. 2008. *L'Art Khmer dans les collections du musée Guimet,* Paris.

Dalet, R. 1937. 'Recherches archéologiques au Cambodge', *BEFEO*, Tome XXXVI, p.23-64. Hanoi.


អត្ថបទដោយ៖ ម៉ង់ វ៉ាលី




រូបលេខ១-២៖ បដិមាព្រះព្រហ្មរកឃើញនៅតំបន់ប្រាសាទវត្តបាសែតតាំងនៅសារមន្ទីរហ្គីមេត




រូបលេខ៣-៤៖ បដិមាព្រះព្រហ្មរកឃើញនៅតំបន់ប្រាសាទវត្តបាសែតតាំងនៅសារមន្ទីរហ្គីមេត

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ៩៖ បដិមាព្រះព្រហ្មរកឃើញនៅតំបន់ប្រាសាទវត្តបាសែតតាំងនៅសារមន្ទីរហ្គីមេត

អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយ៖ ម៉ង់ វ៉ាលី